ធ៧-០៧-១៣២ ប្រ.ក

# ប្រកាស
# ស្តីពី
# ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

**ប្រការ ១**.-

មូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវបានគណនាដូចតទៅ ៖

I- **សរុប** A : ខ្ទង់ត្រូវបូក

- ដើមទុន ឬទាយជ្ជទានដើមទុន
- ទុនបម្រុងក្រៅពីទុនបម្រុងពីការវាយតម្លៃឡើងវិញ
- បុព្វលាភទាក់ទងនឹងដើមទុន (បុព្វលាភភាគហ៊ុន)
- សំវិធានធនចំពោះហានិភ័យទូទៅនៃប្រតិបត្តិការ ដោយមានការយល់ព្រមជាមុនពីធនាគារជាតិនៃកម្ពុជា
- ចំណេញរក្សាទុកសម្រាប់វិនិយោគបន្ត (retained earnings)
- ចំណេញសុទ្ធ ដែលបានផ្ទៀងផ្ទាត់ហើយសម្រាប់ឆ្នាំហិរញ្ញវត្ថុចុងក្រោយ [១]
- ខ្ទង់ផ្សេងៗទៀត ដែលអនុញ្ញាតដោយធនាគារជាតិនៃកម្ពុជា [២] ។

II- **សរុប** B : ខ្ទង់ត្រូវដក

- ចំពោះភាគទុនិក : នាយក នាយកចាត់ការ និងសម្ព័ន្ធញាតិ
  - ចំណែកដើមទុនដែលមិនទាន់បានបង់
  - បុរេប្រទាន ឥណទាន មូលបត្រ និងកិច្ចសន្យារបស់ជនពាក់ព័ន្ធខាងលើ
- ការកាន់កាប់ភាគហ៊ុនផ្ទាល់តាមតម្លៃចុះបញ្ជី
- ការខាតបង្គរ
- ចំណាយក្នុងការផ្តើមបង្កើត
- ការខាតដែលកំណត់តាមគ្រាក្រៅពីការខាតនាចុងការិយបរិច្ឆេទគណនេយ្យប្រចាំឆ្នាំ (រួមបញ្ចូលទាំងសំវិធានធនសម្រាប់បំណុលនិងមូលបត្រសង្ស័យ)។

---

[១] ក្រោយពីដកភាគលាភដែលត្រូវបែងចែក

[២] ឧទាហរណ៍ប្រាក់ចំណេញដែលបានកត់ត្រាតាមគ្រាក្រៅពីប្រាក់ចំណេញនៅចុងការិយបរិច្ឆេទគណនេយ្យប្រចាំឆ្នាំក្នុងលក្ខខណ្ឌដែលៈ

- ប្រាក់ចំណេញនោះត្រូវបានកំណត់ក្រោយពេលបានចុះបញ្ជីនូវចំណាយទាំងអស់ណាដែលទាក់ទងនឹងគ្រានោះ និងចំណាយរំលស់ ព្រមទាំងសំវិធានធន និងតម្លៃគណនីកែតម្រូវ
- ប្រាក់ចំណេញនោះត្រូវបានដកចេញ ពន្ធនិងភាគលាភសុទ្ធដែលនឹងត្រូវបង់ ហើយត្រូវបានផ្ទៀងផ្ទាត់ដោយស្នងការគណនី

III- **សរុប** C : **មូលនិធិផ្ទាល់សុទ្ធមូលដ្ឋាន** = A - B

IV - **សរុប** D: ខ្ទង់ត្រូវបូក

- ទុនបម្រុងពីការវាយតម្លៃឡើងវិញ ដោយមានការយល់ព្រមជាមុនពីធនាគារជាតិនៃកម្ពុជា
- អនុបំណុល (Subordinated debt) ដោយមានការយល់ព្រមជាមុនពីធនាគារជាតិនៃកម្ពុជាអាចបូកបញ្ចូល ១០០% នៃចំនួនមូលនិធិផ្ទាល់សុទ្ធមូលដ្ឋាន
- ខ្ទង់ផ្សេងៗទៀត ដោយមានការយល់ព្រមជាមុនពីធនាគារជាតិនៃកម្ពុជាអាចបូកបញ្ចូលក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធមិនឱ្យលើសពីចំនួននៃមូលនិធិផ្ទាល់សុទ្ធមូលដ្ឋាន[៣]។

V- **សរុប** E: ខ្ទង់ត្រូវដក

- ភាគកម្មមូលនិធិផ្ទាល់ក្នុងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនានា
- ខ្ទង់ផ្សេងៗ [៤]។

VI- **សរុប** F: សរុបមូលនិធិផ្ទាល់សុទ្ធ = C + D - E

**ប្រការ ២**.-

មូលនិធិផ្ទាល់សុទ្ធដែលបានគណនាមកនេះ ត្រូវបានយកមកគិតគូរសម្រាប់ការគណនាអនុបាតប្រុងប្រយ័ត្ន និងអនុបាតផ្សេងទៀត។

**ប្រការ ៣**.-

គ្រឹះស្ថានដែលមិនគោរពតាមខ្លឹមសារនៃប្រកាសនេះ នឹងត្រូវរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ៤**.-

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

---

[៣] ខ្ទង់ផ្សេងៗអាចរួមមានខ្ទង់ទាំងឡាយដូចខាងក្រោមនេះ ÷

- មូលនិធិដែលបានធានាទៅវិញទៅមកយ៉ាងពេញលេញ
- មូលនិធិសាធារណៈដែលបែងចែកសម្រាប់ធានាប្រភេទប្រតិបត្តិការឥណទាន
- ឧបត្ថម្ភធនសាធារណៈ ឬឯកជនដែលមិនត្រូវសងវិញ

[៤] ឧទាហរណ៍ៈ ចំណាយដែលត្រូវបែងចែកសម្រាប់ច្រើនការិយបរិច្ឆេទ

**ប្រការ ៦**.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៧

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**